# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៤៧ សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការកែសំរួលខ្លឹមសារប្រកាសលេខ ៩៦៨ សហវ.ប្រក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រាទី២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម ១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញអនុក្រឹតលេខ ០៤ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៦៨ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ
- បានឃើញលទ្ធផលប្រជុំពិភាក្សាថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** ត្រូវបានកែសំរួលនូវខ្លឹមសារក្នុងប្រកាសលេខ ៤៦៨ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ ត្រង់ប្រការ ៥ ស្តីពីរបបពន្ធ និងហិរញ្ញវត្ថុដូចខាងក្រោម :

**-ចំណុច១** ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវតំកល់ប្រាក់គិតសាធនភាពរបស់ខ្លួននៅរតនាគារជាតិដើម្បីប្រើប្រាស់បើកប្រាក់រង្វាន់ក្នុងករណី ដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុ មិនអាចដោះស្រាយបាន ឬ ក្រុមហ៊ុនក្ស័យធន ។ សាច់ប្រាក់គិតសាធនភាពនេះ

គឺស្មើនឹង ៥០% នៃផលរបរដុល ដោយត្រូវបានកំណត់អប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ទឹកប្រាក់តំកល់នេះអាចដកវិញបាន នៅពេលដែលក្រុមហ៊ុនឆ្នោត-ឡូតូ ឈប់ធ្វើអាជីវកម្ម។

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវតំកល់ប្រាក់កិរិតសាធនភាពរបស់ខ្លួននៅរតនាគារជាតិ ដើម្បីប្រើប្រាស់បើកប្រាក់រង្វាន់ ក្នុងករណីដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុមិនអាចដោះស្រាយបាន ឬក្រុមហ៊ុនក្ស័យធន។ សាច់ប្រាក់កិរិតសាធនភាពនេះ គឺស្មើនឹង ៥០%នៃផលរបរដុល ដោយត្រូវបានកំណត់អប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល)។ ទឹកប្រាក់តំកល់នេះ អាចដកវិញបាន នៅពេលដែលក្រុមហ៊ុនឆ្នោត-ឡូតូ ឈប់ធ្វើអាជីវកម្ម។

-ចំណុច៦ ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវបង់ថ្លៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មឆ្នោត-ឡូតូ សំរាប់រយៈពេល ០៣ ឆ្នាំ ចំនួន ១២០.០០០.០០០ រៀល (មួយរយម្ភៃលានរៀល)។

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូត្រូវបង់ថ្លៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មឆ្នោត-ឡូតូសំរាប់រយៈពេល០៣ ឆ្នាំចំនួន ៩០.០០០.០០០ រៀល (កៅសិបលានរៀល)តែក្រុមហ៊ុនត្រូវបង់ ០១ ឆ្នាំម្តងចំនួន ៣០.០០០.០០០រៀល (សាមសិបលានរៀល)។

-ចំណុច៩ ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវបង់ចំណូលទៅរតនាគារជាតិឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់នូវកាតព្វកិច្ចដែលបានមកពីការធ្វើអាជីវកម្មតាមករណីដូចខាងក្រោម:

-សំរាប់អាជីវកម្មឆ្នោត-ឡូតូ ១ ប្រភេទ (មួយ)

-ចេញ ១ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៤០.០០០.០០០ រៀល/ខែ (សែសិបលានរៀល)

-ចេញ ២ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៦០.០០០.០០០ រៀល/ខែ (ហុកសិបលានរៀល)

-ចេញ ៣ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ១០០.០០០.០០០ រៀល/ខែ (មួយរយលានរៀល)

កែជា: ក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវបង់ចំណូលទៅរតនាគារជាតិ ឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ នូវកាតព្វកិច្ចដែលបានមកពីការធ្វើអាជីវកម្ម តាមករណីដូចខាងក្រោម:

-សំរាប់អាជីវកម្មឆ្នោត-ឡូតូ ១ ប្រភេទ (មួយ) ក្រុមហ៊ុនត្រូវបង់ចំណូលជារបៀបម៉ៅការដោយអនុគ្រោះអោយរួចផុតពីកាតព្វកិច្ចពន្ធដារដូចខាងក្រោម

-ចេញ ១ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ២០.០០០.០០០ រៀល/ខែ (ម្ភៃលានរៀល)

-ចេញ ២ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៤០.០០០.០០០ រៀល/ខែ (សែសិបលានរៀល)

-ចេញ ៣ លើក/ថ្ងៃ ត្រូវបង់គិតជាអប្បបរមា ៦០.០០០.០០០ រៀល/ខែ (ហុកសិបលានរៀល)

**ប្រការ ២ :** ចំពោះប្រភេទឆ្នោតកោស ត្រូវបង់គិតជាអប្បបរមាចំនួន ១០.០០០.០០០ រៀល/ខែ (ដប់លានរៀល)។

**ប្រការ ៣ :** រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤ :** អគ្គលេខាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនឆ្នោត-ឡូតូ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួន។

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"

-ដូចប្រការ ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ